បណ្ណាគារភក្តីច្បាប់
PHEAKDEYLAW BOOK STORE

លេខ : ០១ អនក្រ.បក

# អនុក្រឹត
# ស្តីពី
# ផ្ទេរឥណទានថវិកា

# ១៩៩៧

ផលិតជាសៀវភៅអេឡិចត្រូនិចដោយបណ្ណាគារភក្តីច្បាប់

បានយកសេចក្តីសំរេចក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះរាជហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា ហត្ថលេខា និងត្រា
**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

បង្គំទូលថ្វាយ និង ជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី ១ និង ទី ២
រដ្ឋមន្ត្រីក្រសួងការពារជាតិ
ហត្ថលេខា
**ទៀ បាញ់** **ឌា ច័ន្ទ**

* * *

# II - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១_អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ០១ អនក្រ.បក**

**ស្តីពីការផ្ទេរសេណនាន**

**រាជរដ្ឋាភិបាល**

_ បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
_ បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
_ បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
_ បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តី ពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
_ បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាស អោយប្រើដោយព្រះរាជក្រមនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា

ឆ្នាំ ១៩៩៦

- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០១/ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២៩៥/០៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.ប ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាលស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១ :** ត្រូវបានអនុញ្ញាតផ្ទេរឥណទានពីជំពូក ៤១ (ចំណាយឥតគ្រោងទុក) នៃថវិការដ្ឋចំនួន ២៥៣.៨៣០.០០០ រៀលគត់ (ពីររយហាសិបបីលានប្រាំបីរយសាមសិបពាន់រៀលគត់) បញ្ចូលទៅ ÷

- ជំពូក ១០ (បៀវត្សនិងប្រាក់បំណាច់) ចំនួន ៧៧.២៨០.០០០ រៀលគត់ (ចិតសិបប្រាំពីរលានពីររយប៉ែតសិបពាន់រៀលគត់) ។
- ជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចវប្បធម៌)ចំនួន ១៧៦.៥៥០.០០០ រៀលគត់ (មួយរយចិតសិបប្រាំមួយលានប្រាំរយហាសិបពាន់រៀលគត់) របស់ក្រសួងអប់រំយុវជន និងកីឡាផ្នែកឧត្តមសិក្សា ។

**មាត្រា ២ :** ត្រូវបានអនុញ្ញាតផ្ទេរឥណទានពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាលសំភារៈនិងជួសជុលតូច) ចំនួន ១៣៩.០០០.០០០ រៀលគត់ (មួយរយសាមសិបប្រាំបួនលានរៀលគត់) ទៅជំពូក ១០ (បៀវត្សនិងប្រាក់បំណាច់) របស់ក្រសួងអប់រំយុវជននិងកីឡាផ្នែកអប់រំ ។

**មាត្រា ៣ :** ឥណទានក្នុងមាត្រា ១ និងមាត្រា ២ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់បំពេញបន្ថែមបៀវត្សអាហារូបករណ៍សិស្សនិស្សិត និងប្រាក់ម៉ោងបន្ថែមជូនសាស្ត្រាចារ្យ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

## អនុក្រឹត្យលេខ ០២ អនក្រ.បក
## ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្ម
## សហគ្រាសសាធារណៈ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលេខ ០១ សប្រក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ